ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការសិក្សាស្រាវជ្រាវអំពី "ស្ថានភាពជីវភាពរស់នៅ និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ របស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០២០"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន **លោក លោកស្រីជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត** ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** ទាំងអស់ មេត្តាជ្រាបថា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការសិក្សាស្រាវជ្រាវស្តីពី **"ស្ថានភាពជីវភាពរស់នៅ និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ របស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០២០"** ដែលការធ្វើអង្កេតនេះ នឹងអនុវត្តចាប់ពីថ្ងៃទី **១៧ ដល់ ៣១ ខែកក្កដា ឆ្នាំ២០២០** ទៅលើគំរូសំណាកកម្មករនិយោជិតដែលត្រូវបានជ្រើសរើសដោយចៃដន្យនៅតាមបណ្តារាជធានី ខេត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ **សូម លោក លោកស្រីជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត** ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** ទាំងអស់ មេត្តាជ្រាប និងផ្តល់កិច្ចសហការជាមួយមន្ត្រីសម្ភាសន៍របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ក្នុងការចុះធ្វើអង្កេតនេះ។

ក្នុងករណីមានបញ្ហាទាក់ទងនឹងការអង្កេត ឬត្រូវការព័ត៌មានបន្ថែម សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ៧៥៧ ៩៣៦ និង ០៩៩ ៩៩៩ ៧៩៦។

សូម **លោក លោកស្រីជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត** ក្នុងវិស័យខាងលើ និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ១២ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២០